ទីស្ដីការក្រសួងយុត្តិធម៌

លេខ ១០៧ អគ្គ-២០០២

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
**<u>ផ្ញើរមក</u>**

**ឯកឧត្តមប្រធានតុលាការកំពូល អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល**
**លោកជំទាវប្រធានលសាលាឧទ្ធរណ៍ និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍**
**លោកប្រធានតុលាការ និងលោកព្រះរាជអាជ្ញាអមតុលាការខេត្ត ក្រុង**

**<u>សូមជ្រាប។</u>**

**<u>កម្មវត្ថុ:</u>** អំពីការធ្វើបញ្ជីរាយនាម និងចំនួនវត្ថុតាងដែលត្រូវតុលាការសម្រេចរឹបអូសជាខ្លះសម្បត្តិរដ្ឋ តាមអំណាចសាលក្រម ឬសាលដីកាស្ថាពរ ដើម្បីបញ្ជូនមកក្រសួងយុត្តិធម៌ ។

ខ្ញុំសូមជម្រាបឯកឧត្តម លោកជំទាវ និងអស់លោកឱ្យបានជ្រាបថា ចាប់ពីឆ្នាំ១៩៧៩ រហូតមកដល់ថ្ងៃនេះ វត្ថុតាងដែលតុលាការគ្រប់ជាន់ថ្នាក់បានសម្រេចរឹបអូសបំផ្លាញចោល និងរឹបអូសជាសម្បត្តិរដ្ឋ ក្រសួងពុំដែលបានទទួលរបាយការណ៍ស្ដីអំពីការអនុវត្ត និងចាត់ចែងវត្ថុតាងទាំងនោះទៅតាមសេចក្ដីសម្រេចជាស្ថាពរ របស់តុលាការគ្រប់ជាន់ថ្នាក់នៅឡើយ ដែលជាហេតុធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ជាតិផង និងប៉ះពាល់ដល់ប្រសិទ្ធិភាពនៃការអនុវត្តសេចក្ដីសម្រេចជាស្ថាពររបស់តុលាការគ្រប់ជាន់ថ្នាក់ផង ។

អាស្រ័យហេតុនេះ សូមឯកឧត្តម លោកជំទាវ អស់លោក ចាត់ឱ្យលោកនាយកក្រឡាបញ្ជី ធ្វើបញ្ជីរាយនាម និងចំនួន ព្រមទាំងគុណភាពនៃវត្ថុតាងដែលតុលាការបានសម្រេចរឹបអូសជាសម្បត្តិរដ្ឋតាមអំណាចសាលក្រម ឬសាលដីកាស្ថាពរចាប់ពីឆ្នាំ១៩៧៩ ដល់បំណាច់ឆ្នាំ២០០១ ផ្ញើមកក្រសួងយុត្តិធម៌ឱ្យបានមុនថ្ងៃទី១៥-០២-២០០២ ជាកំហិត និងធ្វើជារៀងរាល់ខែបន្តចាប់ពីខែមករា ២០០២តទៅទៀត ដើម្បីក្រសួងមានវិធានការចាត់ចែងជាផលប្រយោជន៍រដ្ឋឱ្យបានទាន់ពេលវេលា តាមសំណូមពររបស់រាជរដ្ឋាភិបាល ។

រីឯបែបបទ និងនីតិវិធីនៃចំណាត់ការបញ្ចេញវត្ថុតាងទាំងនេះ ប្រគល់ជូនដល់រដ្ឋដើម្បីបានយកទៅប្រើប្រាស់ជាផលប្រយោជន៍ដល់ប្រទេសជាតិយ៉ាងណានោះ ក្រសួងនឹងធ្វើការណែនាំជាក្រោយ ។

សូមឯកឧត្តម លោកជំទាវ និងអស់លោក ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។

សូមជូនភ្ជាប់មកជាមួយនូវគំរូតារាងបញ្ជីរាយនាមវត្ថុតាង ០១ច្បាប់ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០២

**រដ្ឋមន្ត្រី**

**នាង ស៊ីផុង**